- វាយតម្លៃលទ្ធផល នៃកិច្ចសហប្រតិបត្តិការរយៈពេល ០២ ឆ្នាំកន្លងទៅដើម្បីលើកគំរោង និង ទិសដៅនៃកិច្ចសហប្រតិបត្តិការនាឆ្នាំខាងមុខ ។

ប្រការ ៣ : ដើម្បីបំពេញបេសកកម្មខាងលើ គណៈកម្មការមានភារកិច្ច និង សិទ្ធិ ៖

-បង្កើតក្រុមពិសេសប្រចាំឆ្នាំ អ្នកទទួលបន្ទុកអនុវត្តគំរោងផែនការ តាមរយៈពិភាក្សាទ្វេភាគី

-ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីសម្រេច តាមរបាយការណ៍ ឬអតិរេក

-សមាជិកនៃគណៈកម្មការ ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ប្រធាន

-មានសិទ្ធិប្រើត្រា នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តភារកិច្ចពាក់ព័ន្ធចាំបាច់ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងស្ថាប័នពាក់ព័ន្ធដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែមករា ឆ្នាំ ២០០០

## សេចក្តីសម្រេចលេខ ០៤ សសរ
## ស្តីពីការបង្កើតគណៈកម្មការចំរុះ អន្តរក្រសួង
## ដើម្បីទប់ស្កាត់បទល្មើសអនាធិបតេយ្យព្រៃឈើ និង ជីកកំទ្បេង
## នៅស្រុកសំឡូត ខេត្តបាត់ដំបង

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ សេចក្ដីសម្រេចលេខ ០១ ស.ស.រ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ ១៩៩៩ ស្ដីពីវិធានការគ្រប់គ្រង និង លុបបំបាត់ភាពអនាធិបតេយ្យ ក្នុងវិស័យព្រៃឈើ
- យោងសេចក្ដីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការចំរុះអន្តរក្រសួងមួយ ដើម្បីទប់ស្កាត់ភាពអនាធិបតេយ្យក្នុងការកាប់ឈើ និង ជីកដីឥដ្ឋ នៅស្រុកសំឡូត ខេត្តបាត់ដំបង ដែលមានសមាសភាពដូចតទៅ :

-ឯកឧត្ដម យុន ឃាំង រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ជាប្រធាន

-ឯកឧត្ដម ថ្មី សុខា និងឯកឧត្ដម ចាន់ ស៊ីណា សហរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធាន

-ឯកឧត្ដម ចាយ សាំងយុន និងឯកឧត្ដម ម៉ៅ ម៉ុនស្រី សហរដ្ឋលេខាធិការក្រសួងការពារជាតិ ជាអនុប្រធាន

-ឯកឧត្ដម ចន់ ឆុងអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ជាសមាជិក

-ឯកឧត្ដម ញ៉ឹម ម៉ុនជិន រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាសមាជិក

-ឯកឧត្ដម ឆាន់ សាផាន់ រដ្ឋលេខាធិការក្រសួងបរិស្ថាន ជាសមាជិក

-ឯកឧត្ដម ស៊ុយ សែ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ជាសមាជិក

-ឯកឧត្ដម កែ គឹមយ៉ាន អគ្គមេបញ្ជាការរងយោធពលខេមរភូមិន្ទ ជាសមាជិក

-ឯកឧត្ដម ហុក ឡុងឌី អគ្គនាយកនគរបាលជាតិនៃក្រសួងមហាផ្ទៃ ជាសមាជិក

-ឯកឧត្ដម សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាសមាជិក

-ឯកឧត្ដម នៅ ស អភិបាលខេត្តបាត់ដំបង ជាសមាជិក

-លោក ឆាយ សាវុធ ចំណាងលេខាធិការដ្ឋាន អង្គភាពប្រឆាំងការរំលោភអំពើពុករលួយ ជាសមាជិក

ប្រការ ២ : គណៈកម្មការចំរុះខាងលើមានភារកិច្ច និង បេសកកម្មដូចតទៅ :

ក- ចុះត្រួតពិនិត្យស្រាវជ្រាវអោយបានច្បាស់លាស់នូវបទល្មើសជីកដីឥដ្ឋ និងកាប់ព្រៃឈើនៅស្រុកសំឡូត

ខ- ទប់ស្កាត់ជាបន្ទាន់នូវសកម្មភាពអនាធិបតេយ្យ និងរកអោយឃើញបុគ្គលដែលបានប្រព្រឹត្តបទល្មើស

គ- ធ្វើរបាយការណ៍លំអិតអំពីលទ្ធផលនៃការត្រួតពិនិត្យជាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

ប្រការ ៣ : ដើម្បី លក្ខណៈងាយស្រួលដល់ការត្រួតពិនិត្យស្រាវជ្រាវករណីនេះ :

-ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃធ្វើសំណើសុំគោលការណ៍រាជរដ្ឋាភិបាល ផ្លាកការងារជាបណ្ដោះអាសន្នមេបញ្ជាការយោធា ប្រធាននគរបាល និងកងកំលាំងប្រដាប់អាវុធដែលពាក់ព័ន្ធក្នុងការការពារ បើកដៃអោយជនល្មើស ប្រព្រឹត្តនូវអំពើអនាធិបតេយ្យ ដោយតែងតាំងក្រុមការងារមួយសំរាប់បំពេញភារកិច្ចអោយមាននិរន្តរភាពនៅក្នុង ស្រុកសំឡូត

-ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងបរិស្ថាន និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវធ្វើសេចក្តីសំរេចផ្អាកការងារជាបណ្តោះអាសន្ន ចំពោះមន្ត្រីក្រោមឱវាទទាំងអស់ដែលមានការចាប់ខ្លួន និងធ្វើការ តែងតាំងជំនួស បណ្តោះអាសន្នដើម្បីរ៉ាប់រងការងារបន្ត ។

ប្រការ ៨ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

***

## III- ការងារបណ្តាក្រសួង

## នីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០០

**ប្រកាស**

**ប្រកាសលេខ ០២៨/០០ ព.ម.ប្រក**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈ មន្ត្រីរាជការ ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែ សីហា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងពត៌មាន
- ពិនិត្យមើលលក្ខណៈសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ